**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៩១២៩ សហវ.អថ

ថ្ងៃពុធ ១០កើត ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៨

**គោរពជូន**

**ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**កម្មវត្ថុ៖** ករណីសំណើសុំពន្យាពេលអនុវត្តខ្លឹមសារលិខិតលេខ ៨២៤៥ សហវ.អថ ចុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**យោង៖** លិខិតលេខ ៣៦០៨ អយក.មចទ ចុះថ្ងៃទី ០២-០៧-២០១៨ របស់ក្រសួងអប់រំ យុវជន និងកីឡា

តបតាមន័យដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** មេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុញ្ញាតជាគោលការណ៍ជូនក្រសួងអប់រំ យុវជន និងកីឡា ដើម្បីរៀបចំ ប្រឡងសញ្ញាបត្រមធ្យមសិក្សាថ្នាក់ពីរភាសាបារាំង-ខ្មែរឆ្នាំសិក្សា ២០១៧-២០១៨ ។ សម្រាប់ឆ្នាំសិក្សាជាបន្តបន្ទាប់ ក្រសួងអប់រំ យុវជន និងកីឡាត្រូវបន្តអនុវត្តតាមស្មារតីនៃលិខិតលេខ ៨២៤៥ សហវ.អថ ចុះថ្ងៃទី២៧-០៩-២០១៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលនៅជាធរមាន ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងតាមការគួរ។

សូម **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

ចម្លងជូន៖

- អគ្គនាយកដ្ឋានរតនាគារជាតិ
- ឯកសារ-កាលប្បវត្តិ

PO 92

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798